ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

របាយការណ៍
កិច្ចប្រជុំថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែមករា ឆ្នាំ២០២៤
នៅសាលប្រជុំ អ.ជ.ប.ជ.អ

១. សេចក្តីផ្តើម

នៅថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ចាប់ពីម៉ោង៩:00 នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមករា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ម៉ូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ជំនួយការ និងអនុប្រធាននាយកដ្ឋាន នៅបន្ទប់ប្រជុំ "ខ"។

កិច្ចប្រជុំដំណើរការទៅតាមរបៀបវារៈដូចខាក្រោម ៖

១) មតិស្វាគមន៍ និងបើកកម្មវិធីរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២) បង្ហាញរបាយការណ៍ ស្តីពីលទ្ធផលការងារប្រចាំខែធ្នូ ឆ្នាំ២០២៣ និងទិសដៅការងារ ឆ្នាំ២០២៤ ដោយ**ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉ែត**។

៣) បង្ហាញរបាយការណ៍ ស្តីពីកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលយូអិនអេដស៍ (UNAIDS PCB) ដោយ**ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា**។

៤) កិច្ចពិភាក្សា ៖ ក) ការត្រៀមធ្វើវិបស្សនា ខ) ការកិច្ចក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្តព្រះសីហនុ គ) កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស និង ឃ) ផ្សេងៗ

៥) ប្រសាសន៍ថ្នាក់ដឹកនាំ និងបូកសរុបដោយ**ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. ដំណើរការ និងមតិពិភាក្សាលើកិច្ចប្រជុំ

១) មតិស្វាគមន៍ និងបើកកិច្ចប្រជុំរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបើកកិច្ចប្រជុំ និងមានមតិស្វាគមន៍ដល់ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំប្រចាំខែ ដែលជាឱកាសមួយក្នុងការពិនិត្យលើការងាររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកឡើងពីការយកចិត្តទុកដាក់ និងចាប់អារម្មណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើករណីខ្វះថវិកាក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយបានអញ្ជើញអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រជុំពិភាក្សាបង្ហាញពីករណីកង្វះថវិកាក្នុងការងារអេដស៍។ នៅក្នុងកិច្ចពិភាក្សា មានបទបង្ហាញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមានការចូលរួមពីមន្ត្រីពាក់ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវយកចិត្តទុកដាក់ការងារនេះឱ្យបានម៉ឺងម៉ាត់ និងច្បាស់លាស់។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានស្វាគមន៍**ឯកឧត្តមវេជ្ជបណ្ឌិត អ៊ឹង កីរុន** និង**ឯកត្តមវេជ្ជបណ្ឌិត សឹម ស៊ូយេង** ចូលរួមជាអនុប្រធាន និងសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានលើកឡើងទៀតថា៖

- សម្រាប់ឆ្នាំថ្មី មន្ត្រីទាំងអស់ត្រូវមានផ្នត់គំនិតជាមន្ត្រីរាជការសាធារណៈ ត្រូវគោរពតាមការណែនាំរបស់ក្រសួងមុខងារសាធារណៈ។
- ត្រូវយល់ដឹងពីតួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- អគ្គលេខាធិការត្រូវធ្វើបទបញ្ជា និងសេចក្តីណែនាំស្របតាមការណែនាំរបស់ក្រសួងមុខងារសាធារណៈ។
- ធ្វើការងារក្នុងស្មារតីមួយ គឺធ្វើការរួមគ្នាដោយពុំមានការបែងចែកក្រុម ឬបក្សពួកឡើយ។
- ត្រូវពង្រឹងវិន័យការងារ និងពង្រឹងប្រសិទ្ធភាពការងារហើយត្រូវយកចិត្តទុកដាក់ចំពោះការងារ។
- ចំពោះការងារប្រចាំថ្ងៃជាបន្ទុកទទួលខុសត្រូវរបស់ឯកឧត្តមអនុប្រធានប្រចាំការ និងឯកឧត្តមអគ្គលេខាធិការ។
- ការងារខាងមុខ ត្រូវផ្តោតលើការសម្រេចតាមគោលដៅ៩៥ទី១ និងការទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ។

២) របាយការណ៍សកម្មភាពដោយ ឯកឧត្តមបណ្ឌិតឈឹម ឃិនជារ៉ែត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សេចក្តីរាយការណ៍ពីសកម្មភាព លទ្ធផលនានារបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែធ្នូ ឆ្នាំ២០២៣ និងទិសដៅការងារខែមករា ឆ្នាំ២០២៤។

នៅក្នុងបទបង្ហាញបានរាយការណ៍ការងាររបស់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន និងរាយការណ៍វឌ្ឍនភាពឆ្លើយតបនៃអនុសាសន៍នានាក្នុងខែកន្លងមក។

❖ **សកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗក្នុងខែកន្លងមក រួមមាន ៖**

- បានពិនិត្យ និងសម្រេចលើសកម្មភាពនានារបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំពេញអង្គលើកទី២ និងសន្និបាតប្រចាំឆ្នាំ២០២៣ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅខេត្តព្រះសីហនុ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួល UNAISD (PCB) និងបេសកកម្មនានានៅប្រទេសស្វីស។
- បានអញ្ជើញជាគណៈអធិបតីក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ នៅខេត្តត្បូងឃ្មុំ។
- បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៣ និងទិសដៅឆ្នាំ២០២៤ របស់ក្រុមប្រឹក្សាបច្ចេកទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ ពិភាក្សាលើការរៀបចំវិបស្សនាឆ្នាំ២០២៤ ពីរបៀបរបបនៃការធ្វើការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការ ក្រោមអធិបតីភាព ឯកឧត្តមប្រធានស្តីទីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានអញ្ជើញចូលរួមពិធីប្រកាសក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន នៅខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ។
- នាយកដ្ឋានបច្ចេកទេសបានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលតាមបណ្តាខេត្តនានា (ថវិកាជាតិ ថវិកាមូលនិធិសកល និងគម្រោងDFAT) ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត។

❖ **ទិសដៅ និងសកម្មភាពចម្បងៗសម្រាប់ជំហានបន្ទាប់សម្រាប់ឆ្នាំ២០២៤**

- ជំរុញការផ្តល់ចំណេះដឹង ស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការជំរុញការចូលរួមពីក្រុមយុវវ័យក្នុងការងារបង្ការ ការធ្វើតេស្តឈាមរកមេរោគអេដស៍ ឱ្យបានទូលំទូលាយ ដោយការអនុវត្តសកម្មភាពអប់រំ សុខភាពផ្លូវភេទទូលំទូលាយ (Comprehensive Sexual Education) ក្នុងវិស័យអប់រំ។
- ជំរុញភាពជាម្ចាស់ក្នុងការដឹកនាំសម្របសម្រួលការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបន្តអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ (Fast-Track Cities Ending the AIDS Epidemic) និងខេត្តដែល

ទទួលបានថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ៦០លានរៀល (១១ខេត្ត) និង៤០លានរៀល (១០ខេត្ត)។

- ជំរុញការរៀបចំអនុវត្តផែនការសកម្មភាព ថវិកា តាមក្រសួង ស្ថាប័ន ស្របតាមផែនការយុទ្ធសាស្ត្រជាតិលើកទី៦។
- បន្តកៀរគរហិរញ្ញប្បទានក្នុងស្រុក និងក្រៅស្រុក និងកំណត់អាទិភាពសកម្មភាព សម្រាប់ពង្រឹងប្រព័ន្ធជាតិ (Country System) ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ពិសេស សម្រាប់ការងារអេដស៍ នៅថ្នាក់ក្រោមជាតិ។
- បន្តជំរុញអនុវត្តលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ អំពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។
- បន្តផ្សព្វផ្សាយ និងជំរុញការអនុវត្តឱ្យបានទូលំទូលាយ ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ សម្រាប់ឆ្នាំ២០២៤-២០២៨។
- សម្របសម្រួលការរៀបចំផែនការប្រតិបត្តិ (Operational Pan) សម្រាប់ផែនការយុទ្ធសាស្ត្រជាតិលើកទី៦ និងផែនទីបង្ហាញផ្លូវ សម្រាប់និរន្តរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា (SRM)។
- បញ្ចប់ការតាក់តែងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។
- បញ្ចប់ការប៉ាន់ប្រមាណការចំណាយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៨-២០២២ (NASA 7)។
- បញ្ចប់កំណត់ពន្យល់ស្តីពី មាត្រា១៨ មាត្រា១៩ មាត្រា៣៤ មាត្រា៣៥ នៃច្បាប់បង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីសម្រួលដល់បទអន្តរាគមន៍បង្ការ និងជំរុញការធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងចំណោមយុវវ័យអាយុ១៥ឆ្នាំឡើង។
- ការធ្វើការប៉ាន់ប្រមាណមេរោគអេដស៍ថ្នាក់ជាតិ (National HIV Estimates 2024) ដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០២៣។
- បន្តពង្រឹងប្រព័ន្ធព័ត៌មានយុទ្ធសាស្ត្រ (Strategic Information) ស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ (NAA Consolidated HIV Dashboard, CLM Plus S&D, Database on Social Protection..)។

៣)របាយការណ៍ស្តីពីកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលយូអិនអេដស៍ (UNAIDS PCB) **ដោយឯកឧត្តមវេជ្ជបណ្ឌិត ង៉ា ថលា**

- បញ្ហាសំខាន់គឺខ្វះថវិកា (គម្រោង UNAIDS ពុំមានថវិកាគ្រប់គ្រាន់ សម្រាប់ការងារអេដស៍)។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់ពីគោលនយោបាយបញ្ចប់អេដស៍ និងចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

- កម្ពុជាធ្លាប់សម្រេចបានគោលដៅរបស់អង្គការសហប្រជាជាតិបានចំនួនពីរដងរួចមកហើយ ៩០-៩០។ ចំពោះគោលដៅ៩៥ ទី១ បានសម្រេចត្រឹម៨៦% ដោយសារការមិនទទួលស្គាល់ការពិតរឿងការកើនឡើងចំនួនបុរសរួមភេទជាមួយបុរស (MSM)។
- គំរូសេនារីយ៉ូ Optima ឆ្នាំ២០២៣ ត្រូវការ២លានដុល្លាបន្ថែម សម្រាប់ឆ្នាំ២០២៤។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគាំទ្រដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងសូមលើកទឹកចិត្តបន្តឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្តការងារ ដើម្បីបានថវិកាបំពេញបន្ថែមជាមួយដៃគូពាក់ពន្ធ័។
- យុទ្ធសាស្ត្រត្រូវស្វែងរកក្រុមបុរសរួមភេទជាមួយបុរស (MSM) ដើម្បីឱ្យមកធ្វើតេស្តឈាម និងទទួលបានសេវា ARV។
- ត្រូវបន្តពិនិត្យការងាររៀបចំផែនការថវិកានៅតាមបណ្តា២៥ រាជធានី ខេត្ត ដែលមានថវិកា ៨០លាន ៦០លាន និង៤០លានរៀល។
- តួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវពិនិត្យលទ្ធផលទៅលើការងារអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដូចជា៖
  - ✓ តើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ដំណើរការហើយឬនៅ?
  - ✓ តើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត បានប្រជុំទៀងទាត់ និងមានរបាយការណ៍ដែរឬទេ?
  - ✓ តើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត បានរៀបចំផែនការថវិកា និងសកម្មភាពចំណាយហើយឬនៅ?

៤) អិច្ចពិភាក្សា៖ ក) ការត្រៀមធ្វើវិបស្សនា ខ) ការអិច្ចក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្តព្រះសីហនុ គ) អិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស ឯ ឃ) សេចក្តីផ្សេងៗ

- ការត្រៀមធ្វើវិបស្សនាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើប្រធានបទ «រួមគ្នា ឆ្ពោះទៅសម្រេចគោលដៅ ៩៥ ទី១» នាថ្ងៃទី០៥-០៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅខេត្តកែប។
- នៅក្នុងអាណត្តិថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើការកំណែទម្រង់ដ៏មុតស្រួច និងស៊ីជម្រៅ ចំពោះមន្ត្រីរាជការស៊ីវិល ដោយតម្រូវឱ្យមន្ត្រីរាជការស៊ីវិលទាំងអស់ស្តែនមេដៃចូលធ្វើការទៅតាមពេលម៉ោង និងគោលការណែនាំរបស់ក្រសួងមុខងារសាធារណៈ។
- ដើម្បីពង្រឹងប្រសិទ្ធភាពការងារ យើងបានធ្វើសេចក្តីព្រាងគណៈកម្មាធិការវាយតម្លៃ ដើម្បីសុំការសម្រេចរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី។
- ឯកឧត្តមអគ្គលេខាធិការ ត្រូវរៀបចំសេចក្តីសម្រេចសមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ដើម្បីដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីចុះហត្ថលេខា។
- ក្នុងស្ថាប័នអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្នើឱ្យមានយន្តការសម្របសម្រួលរវាងអគ្គលេខាធិការជាមួយថ្នាក់ដឹកនាំជាអនុប្រធានក្នុងការធ្វើការងារអេដស៍។

- ឯកឧត្តមអគ្គលេខាធិការ ត្រូវធ្វើរបាយការណ៍មកឧទ្ធកាល័យរៀងរាល់ខែ ពីសកម្មភាពការងារដែលបានធ្វើ និងលទ្ធផលការងារ ទាំងបញ្ហាប្រឈម និងសំណូមពរផងដែរ។

៥) ប្រសាសន៍ផ្តាក់ដឹកនាំ និងបូកសរុបដោយឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

- តើធ្វើយ៉ាងណា ដើម្បីឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដំណើរការការងារបានល្អ?
- សហការគ្នារវាងថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន ត្រូវរកវិធីសម្របសម្រួលគ្នា ដើម្បីរីកចំរើន និងភាពជោគជ័យរបស់ស្ថាប័ន។
- អាណត្តិថ្មីចង់បានអ្វី ដើម្បីសម្រេចបានគោលដៅ៩៥ ទី១។
- អគ្គលេខាធិការដ្ឋាន ត្រូវរៀបចំគោលការណ៍ស្តែនមេដៃ ដើម្បីពង្រឹងវិន័យមន្ត្រីរាជការស៊ីវិល។
- ស្នើរៀបចំគណៈកម្មាធិការវាយតម្លៃពីថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន ដើម្បីលើកទឹកចិត្ត និងតម្លើងឋានៈមន្ត្រី។
- ចំពោះគណៈកម្មាធិការការវាយតម្លៃថ្នាក់ដឹកនាំ គឺដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី និងគណៈកម្មាធិការការវាយតម្លៃមន្ត្រីអគ្គលេខាធិការដ្ឋាន គឺដឹកនាំដោយ ឯកឧត្តមអគ្គលេខាធិការ។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានមានមតិសំណេះសំណាល បូកសរុបលទ្ធផលក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងប្រកាសបិទកម្មវិធីប្រជុំ។

អង្គប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង ១១:៣៥ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

បានឃើញ និងឯកភាព ប្រធានអង្គប្រជុំ ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ អៀង មូលី	បានឃើញ និងពិនិត្យត្រឹមត្រូវ **អគ្គលេខាធិការ** **បណ្ឌិត ឈឹម យិនដារ៉ែត**	អ្នកធ្វើរបាយការណ៍ **វេជ្ជ. ប៉ែន សេរីវង្ស**